អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**សន្ទរកថាបើកកិច្ចប្រជុំ**

**ឯកឧត្តម គង់ ស្រ៊ីម**

**កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក លើកទី ៧**

**ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១០**

-------------

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា បណ្ដាអង្គការ សារព័ត៌មាននានា ជាទីមេត្រី! ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្ដៅចំពោះការអញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក ពីសំណាក់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ទាំងអស់ ។

ឆ្នាំ ២០១០ នេះ យើងចាប់ផ្ដើមបំពេញកិច្ចការប្រកបដោយសេចក្ដីរំភើបយ៉ាងខ្លាំង ដែលបាន សម្រេចបាននូវជោគជ័យលើភារកិច្ចកន្លងមក ។ មានកិច្ចការសំខាន់ៗជាច្រើនដែល អ.វ.ត.ក សម្រេចបានចាប់តាំងពីកិច្ចប្រជុំពេញអង្គលើកមុន។ សមិទ្ធិផលទាំងនេះ រួមមាន៖ ការបញ្ចប់នូវ សវនាការលើអង្គសេចក្ដីទៅលើជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅ ឌុច ។ សវនាការនេះ បានទាក់ ទាញចំណាប់អារម្មណ៍ពីសាធារណៈយ៉ាងខ្លាំង ហើយតុលាការនេះបានទទួលស្វាគមន៍ភ្ញៀវមកទស្សនា ជិត ៣១០០០ នាក់ នៅសាលសវនាការ ក្នុងអំឡុងពេលសវនាការចំនួន ៧៧ ថ្ងៃ។ អង្គជំនុំ ជម្រះសាលាដំបូងបច្ចុប្បន្ននេះ កំពុងតែធ្វើសេចក្ដីព្រាងសាលក្រម ។ កាលបរិច្ឆេទនៃការចេញសាល ក្រម គឺនឹងប្រកាសដោយអង្គជំនុំជម្រះសាលាដំបូងក្នុងពេលដ៏សមស្រប។ ការិយាល័យសហចៅក្រម ស៊ើបអង្កេត ថ្មីៗនេះក៏បានប្រកាសបិទកិច្ចស៊ើបសួររបស់ខ្លួនក្នុងសំណុំរឿង ០០២ ផងដែរ ។ ជាង នេះទៅទៀត ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ទាំងអស់នឹងមានសេចក្ដី ត្រេកអរនៅពេលដឹងថា ទស្សនាវដ្ដីសារព័ត៌មានសហរដ្ឋអាមេរិកមួយឈ្មោះ Law Technology News of USA បានផ្ដល់រង្វាន់ដល់អ.វ.ត.ក ដោយកោតសរសើរថាអ.វ.ត.ក បាន “ប្រើប្រាស់ បច្ចេកវិទ្យាថ្មីស្រឡាង នៅក្នុងអំឡុងពេលសវនាការ” ។ វិទ្យាស្ថានសាធារណៈរដ្ឋអន្តរជាតិ IRI

បាននិយាយនៅក្នុងការស្ទង់មតិរបស់ខ្លួនដែលធ្វើឡើងរវាងថ្ងៃ៣១កក្កដា ដល់២៦ សីហា ២០០៩ថា ប្រជាជនកម្ពុជា៨២ភាគរយបានយល់ដឹងអំពីការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ហើយប្រជាជន ៧០ភាគរយ បាននិយាយថាការកាត់ទោសខ្មែរក្រហមបាននាំមកនូវយុត្តិធម៌ដល់ពួកគេ។

នៅចុងឆ្នាំ ២០០៩ ប្រធាននៃអង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចមួយបង្គាប់ឱ្យអង្គបុរេជំនុំជម្រះ បំពេញកិច្ចការពេញម៉ោង ។ ប្រការនេះចាត់ទុកថាជាភាពចាំបាច់មួយ ក្នុងការសម្រួលដល់កិច្ចការ ដែលចេះតែកើនឡើង និងភាពចាំបាច់ក្នុងការធានាថាកិច្ចការតុលាការនៅក្នុងសំណុំរឿងលេខ ០០២ អាចសម្រេចទៅបាន តាមពេលវេលាកំណត់ ។ ដោយមានការពិគ្រោះពិភាក្សាជាមួយចៅក្រមអន្តរជាតិមួយចំនួន លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្តល់អនុសាសន៍ថា ចៅក្រមអន្តរជាតិ នៃអង្គបុរេជំនុំជម្រះគួររួមមានសមាសភាព៖ ចៅក្រម Rowan Downing (មកពីអូស្ត្រាលី) និង ចៅក្រម Catherine Marchi-Uhel (មកពីប្រទេសបារាំង)។ ចំណែកចៅក្រម Katinka Lahuis (មកពីប្រទេសហូល្លង់) នឹងក្លាយជាចៅក្រមអន្តរជាតិបម្រុងសម្រាប់អង្គបុរេជំនុំជម្រះ។ ចៅក្រម Florence Mumba (មកពីប្រទេសហ្សំប៊ី) បច្ចុប្បន្នជាចៅក្រមអន្តរជាតិបម្រុង សម្រាប់អង្គបុរេជំនុំជម្រះ នឹងចូលបំពេញដំណែងទំនេរនៅអង្គជំនុំជម្រះតុលាការកំពូល ដែលជាតំណែងរបស់ចៅក្រម Catherine Marchi-Uhel កាលពីមុន ។ ដោយមានការចាត់តាំងពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងការផ្លាស់ប្តូរភារកិច្ច នៅក្នុងអង្គជំនុំជម្រះនានា បច្ចុប្បន្នកិច្ចការនេះកំពុងស្ថិតនៅក្នុងសមត្ថកិច្ច នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីអនុម័តយល់ព្រម និង ការតែងតាំងដោយព្រះរាជក្រឹត្យ នាពេលខាងមុខនេះ ។

កិច្ចប្រជុំពេញអង្គនេះ គឺជាកាលានុវត្តភាពផ្លូវការលើកទីមួយរបស់ខ្ញុំ ក្នុងការស្វាគមន៍សហព្រះរាជអាជ្ញាអន្តរជាតិនៃ អ.វ.ត.ក លោក Andrew Cayley និង សហព្រះរាជអាជ្ញា អន្តរជាតិបម្រុង លោក Nicholas Koumjian (នីកូលាស គូមជែន)។ លោកទាំងពីរ សុទ្ធតែមានប្រវត្តិល្បីក្នុងការបម្រើការ នៅតុលាការដែលមានលក្ខណៈអន្តរជាតិជាច្រើន។ តាងនាមឱ្យ អ.វ.ត.ក ទាំងមូល ខ្ញុំសូមសំដែងការស្វាគមន៍ដ៏កក់ក្តៅ ។ បន្ទាប់ពីអនុប្រធានកិច្ចប្រជុំពេញអង្គដែលជាសមភាគីអន្តរជាតិ បានបញ្ចប់សន្ទរកថារបស់ខ្លួនភ្លាម នឹងមានកិច្ចសច្ចាប្រណិធានចូលកាន់មុខដំណែង។

ឆ្លៀងក្នុងឱកាសនេះខ្ញុំសូមទាញចំណាប់អារម្មណ៍របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ទាំងអស់ថា កិច្ចប្រជុំពេញអង្គនេះមានគោលបំណងជាក់លាក់មួយ គឺធ្វើយ៉ាងណាដើម្បីអនុម័តនូវវិសោធនកម្មទៅលើវិធានផ្ទៃក្នុង អ.វ.ត.ក ដែលសំដៅធ្វើឲ្យមានប្រសិទ្ធភាព និងពង្រឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធី អ.វ.ត.ក ។ វិសោធនកម្មទាំងនេះ គឺមានលក្ខណៈចាំបាច់ក្នុងការធានាបាននូវសមត្ថភាព អ.វ.ត.ក ក្នុងការចាត់ចែងដោះស្រាយ ចំពោះពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងលេខ ០០២ ដោយហេតុថាសំណុំរឿងនេះមានអ្នកដាក់ពាក្យបណ្តឹងច្រើន ហើយមានលក្ខណៈស្មុគ្រស្មាញទៀតផង ។ គិតមកត្រឹមថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១០ អង្គភាពជនរងគ្រោះទទួលទម្រង់ព័ត៌មានជនរងគ្រោះចំនួន **៨១៩០** ដែលក្នុងនោះមាន ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤០០៤ ។ **(តួលេខបច្ចុប្បន្នភាពពេលទទួលពីអង្គភាពជនរងគ្រោះ)** ។ វិសោធនកម្មទាំងនេះ ចាត់ចែងទៅលើតម្រូវការចាំបាច់ ឲ្យមានបណ្តឹងដែលទាមទារសំណងជាសមូហភាព និង សំណងជំងឺចិត្តរួមមួយ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលក្ខណៈជាក្រុមតែមួយរួមគ្នា នឹងត្រូវតំណាងដោយសហមេធាវីមួយក្រុម ដែលគាំទ្រដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

ខ្ញុំសូមរំលឹកជូនថា កិច្ចប្រជុំពេញអង្គលើកមុន បានអនុមត័វិសោធនកម្មមួយ ដែលផ្លាស់ប្តូរការកំណត់ពេលវេលាដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ ១៥ ថ្ងៃ ក្រោយពីការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ។ ពេលវេលាកំណត់ឈប់ទទួលពាក្យបានផុតកំណត់ថ្ងៃ ទី ២៩ ខែ មករា ឆ្នាំ ២០១០ ។ ជាងនេះទៅទៀត គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងបានអនុម័តទៅលើទម្រង់ព័ត៌មានជនរងគ្រោះ ដែលមានការកែលំអយ៉ាងច្រើន និងកាន់តែសាមញ្ញមានប្រសិទ្ធិភាព ហើយត្រូវបានបង្ហាញនៅក្នុងគេហទំព័រ អ.វ.ត.ក មុនកាលបរិច្ឆេទឈប់ទទួល ពាក្យ ។

វិសោធនកម្មមួយចំនួន ដែលចាំបាច់បំផុតត្រូវបានអនុម័ត កាលពីកិច្ចប្រជុំពេញអង្គលើកមុនក៏ពិតមែន ប៉ុន្តែ វាជាការសំខាន់ណាស់ដែលត្រូវផ្តល់នូវការគិតពិចារណាឲ្យបានសមស្របនៅក្នុង ការកែទម្រង់ផ្សេងៗទៀតដែលមានលក្ខណៈចាំបាច់ សម្រាប់ដំណាក់កាលមុនជំនុំជម្រះ និង

ដំណាក់កាលជំនុំជម្រះ លើសំណុំរឿងលេខ ០០២ នៅក្នុងរយៈពេលនៃកិច្ចប្រជុំពេញអង្គនាពេលនេះ ។ នៅក្នុងកិច្ចប្រជុំកាលនោះ អនុគណៈកម្មាធិការរួមមាន សមាសភាពចៅក្រម និង បុគ្គលិក ជាតិ និង អន្តរជាតិ មានភារកិច្ចធ្វើសេចក្តីព្រាងវិសោធនកម្មផ្នែកបច្ចេកទេសទៅលើវិធានផ្ទៃក្នុង ។ អនុគណៈកម្មាធិការបានពិគ្រោះពិភាក្សា យ៉ាងជិតដិតជាមួយ អង្គភាពជនរងគ្រោះ ការិយាល័យសហចៅក្រម ការិយាល័យសហព្រះរាជអាជ្ញា និង ផ្នែកគាំពារការការពារក្តី ។ នៅពេលបញ្ចប់សេចក្តីព្រាងរបស់ខ្លួនរួចហើយ អនុគណៈកម្មការនេះបានចែកចាយសេចក្តីព្រាងវិសោធនកម្មនោះ ។ បន្ទាប់មក គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងបានជួបប្រជុំពីថ្ងៃទី ៣ ដល់ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០០៩ ដើម្បីពិចារណាទៅលើសំណើនានារបស់អនុគណៈកម្មាធិការ ក៏ដូចជាមតិយោបល់ពីការិយាល័យនានា ដែលបានរៀបរាប់ខាងលើ ។

ក្រោយពីបានពិភាក្សាសម្រេច និង ការកែប្រែបន្ថែមទៀតទៅលើសំណើមួយចំនួនរួចមក គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងបានបញ្ជូនវិធានវិសោធនកម្មដែលស្នើឡើងនេះជូនកិច្ចប្រជុំពេញអង្គ ដើម្បីពិចារណា។

គួររំលឹកផងដែរថា កិច្ចប្រជុំពេញអង្គកាលពីលើកមុនក៏បានសម្រេចអនុម័តយកនូវទម្រង់បន្ថែមផ្សេងៗទៀតទាក់ទងនឹងការចូលរួមរបស់ជនរងគ្រោះ ដែលទម្រង់ទាំងនេះនឹងចេញជារូបរាងឡើងក្រៅក្របខ័ណ្ឌនីតិវិធីតុលាការផ្លូវការ ។ វិធានវិសោធនកម្មដែលស្នើឡើងដែលកំពុងស្ថិតក្នុងការពិចារណានៅក្នុងកិច្ចប្រជុំពេញអង្គនាពេលនេះ គឺមានវិធានការនានាដែលអាចធ្វើឲ្យប្រសើរឡើងដល់សមត្ថភាពនៃ អង្គភាពជនរងគ្រោះនៅក្នុងវិស័យនេះ ។ ប្រការនេះផ្តល់នូវកាលានុវត្តភាព គំរូមួយសម្រាប់ឆ្លុះបញ្ចាំងអំពីគោលបំណងខ្ពស់បំផុត នៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណាក់កាលនីតិវិធីនានានៃ អ.វ.ត.ក ។ វាក៏ជាការឆ្លុះបញ្ចាំងផងដែរថា តើវិធីណាជាវិធីល្អបំផុតក្នុងការបម្រើសេចក្តីត្រូវការរបស់ជនរងគ្រោះទាំងអស់ នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការប្រើប្រាស់ ដ៏សកម្មនូវធនធាន ដើម្បីជួយយើងក្នុងការសម្រេចឲ្យខាងតែបាននូវគោលដៅនានា ដែលបានកំណត់ទុក ។

កិច្ចប្រជុំពេញអង្គនេះ ផ្តល់ឱកាសចូលរួមយ៉ាងសកម្ម ក្នុងការនាំមកនូវជោគជ័យ សម្រាប់ដំណាក់កាលបន្ទាប់ទៀតនៃជីវិតការងាររបស់ អ.វ.ត.ក ។ ទោះបីជាសវនាការលើសំណុំរឿងក្តីបានបញ្ចប់ទៅប្រកបដោយជោគជ័យយ៉ាងណាក្តី ក៏នៅមានការប្រឈមជាច្រើនទៀត ដែលក្នុង

នោះរួមមានការសម្រេចកិច្ចការនេះ ទៅតាមពេលវេលាដែលបានព្រមព្រៀងគ្នា ។ តាមរយៈការចូលរួម ការបញ្ចេញមតិយោបល់ប្រកបដោយន័យស្ថាបនា និង ការពិចារណា សម្រេចប្រកបដោយប្រសិទ្ធភាព នៅក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ យើងធានាឲ្យបានថែមទៀតនូវកិច្ចការ របស់ អ.វ.ត.ក នៅពេលអនាគត និង តាំងចិត្តសាជាថ្មីចំពោះបេសកកម្ម នៃការផ្តល់យុត្តិធម៌ ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពជូនចំពោះជនរងគ្រោះទាំងអស់ នៃរបបកម្ពុជាប្រជាធិបេតយ្យ។

សូមអរគុណ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ទាំងអស់ ។